ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
**************

សាលាឧទ្ធរណ៍ភ្នំពេញ
សំណុំរឿងព្រហ្មទណ្ឌ
លេខ: ១៣ / ១៧.០១.២០០៥
សាលដីកា
លេខ:១០៦ ក្រ.III.ស/២៦.១២.២០១៣

# ក្នុងនាមប្រជារាស្ត្រខ្មែរ
# សាលាឧទ្ធរណ៍ភ្នំពេញ

បានបើកសវនាការជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ដោយមានសមាសភាពដូចតទៅ:

**ក្រុមប្រឹក្សាជំនុំជម្រះ**

លោក [redacted] ជាប្រធាន

លោក [redacted] ជាចៅក្រមប្រឹក្សា

លោក [redacted] ជាចៅក្រមប្រឹក្សា

**តំណាងមហាអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជី**

កញ្ញា [redacted]

ដើម្បីធ្វើការជំនុំជម្រះលើបណ្តឹងទាស់ នៃសំណុំរឿងព្រហ្មទណ្ឌលេខ ១៣ ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៥ រវាង៖

ជនជាប់ចោទឈ្មោះ [redacted] សុខខែម ហៅ ចិនខ្មៅ ភេទប្រុស អាយុ៤៦ឆ្នាំ ជាតិខ្មែរ កំរិតវប្បធម៌ថ្នាក់ទី៨ មុខរបរៈកម្មករ ទីកន្លែងកំណើត ភូមិគគរ ឃុំគគរ ស្រុកក្រចេះ ខេត្តក្រចេះ ទីលំនៅបច្ចុប្បន្ន [redacted] ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ឪពុកឈ្មោះ [redacted] (ស) ម្តាយឈ្មោះ [redacted] (រ) ប្រពន្ធឈ្មោះ [redacted] (លែងលះ) មានកូន០៣នាក់ ទោសពីមុនគ្មាន ចាប់ខ្លួនថ្ងៃទី១៧ ខែមករា ឆ្នាំ២០០៤។

មានកញ្ញា [redacted] សុខហ៊ិន ជាមេធាវីការពារ។

ជាប់ចោទពីបទៈ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌ ដែលមានចែង និងឲ្យផ្តន្ទាទោសតាមមាត្រា ៣ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] សេងហាវ ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

ដើមបណ្តឹងរដ្ឋប្បវេណីឈ្មោះ [redacted] ម៉ៅ ភេទស្រី អាយុ៣៩ឆ្នាំ ជាតិខ្មែរ បច្ចុប្បន្នរស់នៅ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ។

៦ដំណើររឿងមានដូចតទៅ ៖

កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ វេលាម៉ោង២០ និង៤០នាទីយប់ មានករណីប្លន់សម្លាប់កើតឡើង នៅចំណុចភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ ហើយក្រុមចោរនេះបានបាញ់សម្លាប់ជនរងគ្រោះពីរនាក់ឈ្មោះ [redacted] ចាន់ ភេទប្រុស អាយុ៤៧ឆ្នាំ និងឈ្មោ[redacted]ឡាង ភេទប្រុស អាយុ៤៨ឆ្នាំ ក្រោយពេលក្រុមចោរបានធ្វើសកម្មភាពប្លន់សម្លាប់រួចក្រុមចោរទាំងនោះត្រូវសមត្ថកិច្ចចាប់ខ្លួនជាបន្តបន្ទាប់។

បានឃើញ សាលក្រមព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី០៩, ១០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ផ្តន្ទាទោសលើឈ្មោះ [redacted] សូត្រ (ញ៉ាញ់) ដាក់ពន្ធនាគារកំណត់មួយឆ្នាំគត់ តែទោសនេះឲ្យឈ្មោះ ម៉ែន សូត្រ ទទួលការព្យួរសាកល្បងរយៈពេល៥ឆ្នាំ គិតពីថ្ងៃប្រកាសសាលក្រមនេះតទៅ ពីបទ កាន់កាប់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌ និងការផ្តន្ទាទោសមានបញ្ញត្តិក្នុងមាត្រា ៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល ចុះថ្ងៃទី១០ ខែកញ្ញា ឆ្នាំ១៩៩២។

២- ផ្តន្ទាទោសលើឈ្មោះ

ក. [redacted] សាវង្ស ហៅ ប៊ុប

ខ. [redacted] ង៉ាន ហៅ [redacted] យូឌី

គ. [redacted] សុខខែម ហៅ ចិនខ្មៅ

ឃ. [redacted] វុធដា ដាក់ពន្ធនាគារតម្រូវឲ្យធ្វើការក្នុងម្នាក់ៗ កំណត់ ១៥ឆ្នាំ(ដប់ប្រាំឆ្នាំ) គិតពីថ្ងៃឃុំខ្លួននៅពន្ធនាគារ ថ្ងៃទី២២ ខែមករា ឆ្នាំ២០០៤ ពីបទ ធ្វើមនុស្សឃាតចេតនាគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅ ភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ បទល្មើសព្រហ្មទណ្ឌ ទណ្ឌកម្ម និងការផ្តន្ទាទោសដែលមានបញ្ញត្តិក្នុងមាត្រា ៣ និងមាត្រា ៥៤ នៃច្បាប់ស្តីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៣- បង្គាប់ឲ្យឈ្មោះ [redacted] សាវង្ស (ប៊ុប), [redacted] ង៉ាន ហៅ [redacted] យូឌី, [redacted] សុខខែម ហៅ ចិនខ្មៅ និង [redacted] វុធដា រួមគ្នាសងសំណងការអន្តរាយឲ្យទៅឈ្មោះ [redacted] សៀងហាវ ចំនួន២៥ម៉ឺនបាត (ម្ភៃប្រាំម៉ឺនបាត) ឈ្មោះ គង់ សៀងហាវ ទារលើសពីនេះបដិសេធចោល។ ក្នុងករណីឈ្មោះ [redacted] សាវង្ស ហៅ ប៊ុប[redacted]ង៉ាន ហៅ [redacted]យូឌី, [redacted]សុខខែម ហៅ ចិនខ្មៅ និងឈ្មោះ[redacted]វុធដា គ្មានប្រាក់សងធនទណ្ឌគ្រប់ចំនួនទេនោះ ត្រូវដាក់គុកបង្ខំរូបកាយកំណត់ពីរឆ្នាំទៀតយ៉ាងយូរ ដើម្បីបង្ខំទារធនទណ្ឌ។ តាមបញ្ញត្តិមាត្រា៧ និងមាត្រា១០ នៃច្បាប់ស្តីពីការដាក់គុកបង្ខំដល់រូបកាយក្នុងរឿងព្រហ្មទណ្ឌ ដែលប្រកាសឲ្យប្រើតាមក្រឹត្យលេខ ១៨ក្រ ចុះថ្ងៃទី០៨ ខែកុម្ភៈ ឆ្នាំ១៩៩២។ ៚

៤- វត្ថុតាងមានៈ

- គំរបគ្រាប់បែកធ្វើអំពីជ័រប្លាស្ទិក ចំនួនមួយ ពណ៌អាចម៍សេះ។
- ខ្សែគន្លឹះគ្រាប់ ចំនួនមួយ ប្រវែង០,១៤ម៉ែត្រ ពណ៌ស។
- អំបែងគ្រាប់បែកចំនួន ១២គ្រាប់។
- សំបកកាទូសកា៥៤ លេខ២១៥៤ ចំនួនមួយគ្រាប់។
- សំបកគ្រាប់បែក ចំនួនមួយគ្រាប់ លេខ២១៥៤អំបែងគ្រាប់ ចំនួនអំបែងកេះដែកធ្វើអំពីបន្ទះស័ង្កសីរាងបួនជ្រុង បណ្តោយ១៨០ស.ម ទទឹង៣០ស.ម កំពស់២៤,១ស.ម និងអាវដៃវែងពណ៌អាចម៍សេះ ចំនួនមួយ មានប្រឡាក់ឈាម។ វត្ថុតាងនេះ ត្រូវរឹបអូសបំផ្លាញចោល។
- កាំភ្លើងអាកាស្វាយបត់លេខ៥១២៩ ចំនួនមួយដើម។
- កាំភ្លើងខ្លី ម៉ាកកា៥៤ លេខអ៊ីអេៈ០២៤៧៣៤ ផលិតនៅប្រទេសចិន ចំនួនមួយដើម គ្រាប់៥គ្រាប់បង់មួយ។
- កាំភ្លើងខ្លីធុនរ៉ូឡូលេខ៧៨ គ្រាប់៣គ្រាប់ បង់ចំនួនមួយ។

វត្ថុទាំងនេះ ត្រូវរឹបអូសដាក់ជាសម្បត្តិរដ្ឋ និងប្រគល់ឲ្យទៅអគ្គនាយកនគរបាលជាតិ ជាអ្នកគ្រប់គ្រងនៅពេលសាលក្រមមានអានុភាពអនុវត្ត។

៥- សាលក្រមនេះ ប្រកាសជាសាធារណៈ ចំពោះមុខជនជាប់ចោទទាំងបួននាក់ កំបាំងមុខជនជាប់ចោទឈ្មោះ [redacted] សូត្រ ហៅ ញ៉ាញ់ ចំពោះមុខដើមបណ្តឹងរដ្ឋប្បវេណី នៅថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០០៤ ហើយបើកផ្លូវប្តឹងទាស់ និងឧទ្ធរណ៍ក្នុងកំណត់ច្បាប់។

បានឃើញបណ្តឹងឧទ្ធរណ៍ លេខ ៣០ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤ របស់ជនជាប់ចោទឈ្មោះ [redacted] វុធដា, ឈ្មោះ [redacted] សារ័ង្ស ហៅ ប៊ុប, ឈ្មោះ [redacted] ង៉ាន ហៅ [redacted] យូឌី និងឈ្មោះ [redacted] សុខខែម ហៅ ចិនខ្មៅ ប្តឹងឧទ្ធរណ៍នឹងសាលក្រមព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី០៩, ១០ ខែកញ្ញា ឆ្នាំ២០០៤ របស់សាលាដំបូងខេត្តបន្ទាយមានជ័យ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

បានឃើញ សាលដីកាព្រហ្មទណ្ឌលេខ ២៣ «ក» ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ដែលមានខ្លឹមសារនៃសេចក្តីសម្រេចដូចតទៅៈ

១- ទទួលបណ្តឹងឧទ្ធរណ៍ ៣០ ចុះថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០០៤ របស់ជនជាប់ចោទឈ្មោះ [redacted] វុធដា, [redacted] សារ័ង្ស ហៅ ប៊ុប [redacted] ង៉ាន ហៅ យូឌី និង [redacted] សុខខែម ហៅ ចិនខ្មៅ ទុកជាត្រឹមត្រូវតាមទម្រង់ច្បាប់ តែបដិសេធចោលដោយផ្ទុយនឹងគតិច្បាប់។

២- ទទួលលោក [redacted] ឡៃហេង ជាមេធាវីការពារជនជាប់ចោទ ត្រឹមត្រូវតាមច្បាប់។

៣- តម្កល់សាលក្រមព្រហ្មទណ្ឌលេខ ១៧៥ ចុះថ្ងៃទី០៩,១០ ខែកញ្ញា ឆ្នាំ២០០៤ របស់តុលាការ

ខេត្តបន្ទាយមានជ័យ ទុកជាបានការពេញទាំងមូល។

សាលដីកានេះ ជំនុំជម្រះ និងប្រកាសជាសាធារណៈ ចំពោះមុខមេធាវីការពារជនជាប់ចោទ កំបាំងមុខជនជាប់ចោទ និងដើមបណ្តឹងរដ្ឋប្បវេណី, បើកផ្លូវតវ៉ាតាមកំណត់ច្បាប់។

បានឃើញបណ្តឹងទាស់លេខ ១៦ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ របស់ជនជាប់ចោទឈ្មោះ [redacted] សុខខែម ហៅ ចិនខ្មៅ ប្តឹងទាស់នឹងសាលដីកាព្រហ្មទណ្ឌលេខ ២៣ «ខ» ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ត្រង់ចំណុចទាំងមូលនៃសេចក្តីសម្រេច។

## នាពេលសវនាការ

ប្រធានក្រុមប្រឹក្សា បញ្ជាក់អង្គហេតុរឿងជូនអង្គសវនាការ

ក្រឡាបញ្ជីអានចម្លើយដើមបណ្តឹរដ្ឋប្បវេណីឈ្មោះ [redacted] សេងហាវ និងឈ្មោះ [redacted] ម៉ៅឆ្លើយនៅសាលាដំបូងខេត្តបន្ទាយមានជ័យ។

ជនជាប់ចោទឈ្មោះ [redacted] សុខខែម ឆ្លើយថា ខ្លួនពុំបានប្រព្រឹត្ត ឬ ចូលរួមប្រព្រឹត្ត ធ្វើសកម្មភាពដូចការចោទប្រកាន់ទេ, ផ្ទះខ្លួននៅឆ្ងាយពីកន្លែងកើតហេតុ ប្រមាណដប់គីឡូម៉ែត្រ។ នៅថ្ងៃកើតហេតុ ខ្លួននៅផ្ទះពេញមួយថ្ងៃ មិនអាចមកចូលរួមប្រព្រឹត្តបានទេ នៅពេលនោះមិត្តភ័ក្រ្តបានហៅខ្លួន ទៅបរិភោគបាយនៅផ្ទះតាប៊ី មានអ្នកចូលរួមជាច្រើននាក់ដែរ, ខ្លួននៅផឹកស៊ីរហូតដល់ម៉ោង២២ ទើបត្រឡប់ទៅផ្ទះដេក។ ខ្លួនជាប់ពន្ធនាគារចំនួនដប់ឆ្នាំហើយ សូមតុលាការជួយរកយុត្តិធម៌ដល់ខ្លួនផង។

## សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

បណ្តឹងទាស់របស់ជនជាប់ចោទឈ្មោះ [redacted] សុខខែម ធ្វើឡើងត្រឹមត្រូវតាមទម្រង់ច្បាប់ ដោយរឿងនេះសកម្មភាពដែលប្រព្រឹត្តបទល្មើស និងសកម្មភាពប្លន់សម្លាប់មនុស្ស ជនជាប់ចោទបានឆ្លើយបដិសេធរហូតតាំងពីសាលាដំបូង និងនៅសវនាការសាលាឧទ្ធរណ៍នាពេលនេះ ហើយបើពិនិត្យទៅឃើញថា ករណីនេះមានភស្តុតាងត្រឹមតែចម្លើយឆ្លើយដាក់ប៉ុណ្ណោះ ហើយអរត់ឃើញមានសំអាងអីផ្សេងទៀតដែរ ដូចនេះតំណាងមហាអយ្យការជូនទៅក្រុមប្រឹក្សាពិនិត្យ ពិចារណា និងសម្រេចតាមច្បាប់។

## សេចក្តីសន្និដ្ឋានរបស់មេធាវី

នៅក្នុងរឿងនេះខ្លួនសូមបញ្ជាក់ថា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ នោះ កូនក្តីខ្លួនអត់បាននៅកន្លែងកើតហេតុទេ គឺគាត់នៅផ្ទះតាប៊ី ហើយនៅក្នុងពេលនោះ មានសាក្សីផ្សេងៗដែលបានដឹងឮថា គាត់នៅជាមួយគ្នា និងបានមើលកុន និងហូបបាយជាមួយគ្នាទៀត ដែលមានឈ្មោះ តាចិត្ត ប្រពន្ធរបស់គាត់ ឈ្មោះឡេង និងឈ្មោះឡូវ និងមានសាក្សីផ្សេងៗទៀតនៅកន្លែងដែលគាត់បានហូបបាយនោះ ហើយកូនក្តីខ្លួនបានបញ្ជាក់ហើយថា នៅថ្ងៃកើតហេតុនោះ គាត់នៅតាំងពីម៉ោងក្បាលល្ងាចរហូតដល់ម៉ោងដប់យប់ បើយើងវិភាគទៅលើកន្លែងកើតហេតុ ទៅនឹងកន្លែងដែលគាត់បានហូបបាយនៅភូមិអូរ គឺមានចម្ងាយពីគ្នាដប់គីឡូម៉ែត្រ តើគាត់អាចទៅប្រព្រឹត្តបទល្មើសប្លន់បានដែរឬទេ ក្នុងករណីនេះ ចំណុច១ ទាក់ទងទៅនឹងចម្ងាយផ្លូវ ទី២ ទាក់ទងទៅនឹងសាក្សីនៅកន្លែងកើតហេតុ ទី៣ ទាក់ទងទៅនឹងការចាប់ខ្លួន ប៉ូលីសមិនបានចាប់ខ្លួនគាត់នៅទីកន្លែងកើត

ហេតុជាក់ស្តែងទេ គឺក្រោយកើតហេតុ២-៣ថ្ងៃ គឺមិនមែនជាបទល្មើសជាក់ស្តែងទេ ទី៤ទាក់ទងទៅនឹងសាក្សី ដែលនៅកន្លែងកើតហេតុ មានជាច្រើនគាត់បានបង្ហាញពីភិនភាគរបស់ជនល្មើសដែលបានចូលទៅប្លន់ ពីស្ថានភាព ពីអាវ ពីអាវុធផ្សេងៗ គឺអត់មានសាក្សីណាមួយបញ្ជាក់ថាជនល្មើសស្រដៀងទៅនឹងកូនក្តីខ្លួនទេ ចំណុចទី៥ ទាក់ទងទៅនឹងការស្រាវជ្រាវរកភស្តុតាងរបស់ប៉ូលីស មិនបានបញ្ជាក់នូវភស្តុតាងឬសាក្សីណាផ្សេងៗ ដែលនៅកន្លែងកើតហេតុដែលអាចបញ្ជាក់ថា កូនក្តីខ្លួនបានចូលរួមក្នុងការប្រព្រឹត្តនូវបទល្មើសឡើយ ហើយមួយទៀត ទាក់ទងទៅនឹងចម្លើយរបស់គាត់បានឆ្លើយនៅប៉ូលីស នៅអយ្យការ និងនៅចៅក្រមស៊ើប ក៏ដូចជានៅពេលជម្រះ គឺគាត់បដិសេធថាមិនបានចូលរួមទេ។ ទាក់ទងទៅនឹងចម្លើយរបស់ជនជាប់ចោទ ផ្សេងទៀត ដែលបានឆ្លើយដាក់បន្ទុកទៅលើគាត់ ដូចជាឈ្មោះ[redacted] ជឿន, ឈ្មោះ [redacted] សារ៉ាត់ ដែលថា កូនក្តីខ្លួនចូលរួមនោះ ជាចម្លើយមិនពិតទេ សូម្បីតែលោកតំណាងមហាអយ្យការក៏បានបញ្ជាក់ដែរថា គ្មានភស្តុតាង គ្មានសាក្សីណាដាក់បន្ទុកទៅលើកូនក្តីខ្លួនដែរ សូមលោកប្រធានក្រុមប្រឹក្សាជំនុំជម្រះមេត្តាបដិសេធ សាលដីកាកំបាំងមុខ និងសម្រេចលើកលែងចោទប្រកាន់ដល់កូនក្តីខ្លួនឈ្មោះ [redacted]សុខខែម ដោយអនុគ្រោះ។

ក្រោយពីបានស្តាប់ចម្លើយជនជាប់ចោទ

ក្រោយពីបានស្តាប់អំណានចម្លើយដើមបណ្តឹងរដ្ឋប្បវេណី

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងមហាអយ្យការ

ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់មេធាវីការពារជនជាប់ចោទ

ក្រោយពីបានពិភាក្សា ជជែកញែក ល្អិតល្អន់ តាមច្បាប់

## សភាព្រហ្មទណ្ឌ

## យល់ឃើញថា:

១. បណ្តឹងទាស់លេខ ១៦ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ របស់ឈ្មោះ[redacted] សុខខែម ជាជនជាប់ចោទ ធ្វើក្នុងកំណត់ច្បាប់ តាមមាត្រា ៤១០ នៃក្រមនីតិវិធីព្រហ្មទណ្ឌ។

២. តាមចម្លើយជនជាប់ចោទ នៅសវនាការនេះ ក៏ដូចនៅសាលាដំបូងថា ខ្លួនពុំបានប្រព្រឹត្ត ឬ ចូលរួមប្រព្រឹត្ត ធ្វើសកម្មភាពដូចការចោទប្រកាន់ទេ, ផ្ទះខ្លួននៅឆ្ងាយពីកន្លែងកើតហេតុ ប្រមាណដប់គីឡូម៉ែត្រ។ នៅថ្ងៃកើតហេតុ ខ្លួននៅផ្ទះពេញមួយថ្ងៃ មិនអាចមកចូលរួមប្រព្រឹត្តបានទេ នៅពេលនោះ មិត្តភ័ក្តិបានហៅខ្លួនទៅបរិភោគបាយនៅផ្ទះតាប៊ី មានអ្នកចូលរួមជាច្រើននាក់ដែរ, ខ្លួននៅផឹកស៊ីរហូតដល់ម៉ោង២២ ទើបត្រឡប់ទៅផ្ទះដេក។

៣. ១. តាមចម្លើយរបស់ឈ្មោះ[redacted] សារ៉ាន់ ថា នៅថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ បក្សពួកខ្លួនមាន សូត្រ [redacted] សូត្រ), ង៉ាន ([redacted] ង៉ាន), សាវង្ស[redacted] សាវង្ស), សុខខែម [redacted] សុខខែម), វុធដា[redacted] វុធដា) និងខ្លួន ([redacted] សារ៉ាន់) និងពីរ បីនាក់ទៀតមិនស្គាល់ឈ្មោះ។

ពេលធ្វើសកម្មភាពឈ្មោះ[redacted] សុខខែម និងឈ្មោះ ជឿន នៅចាំផ្លូវខាងជើង។

៣. ២. តាមចម្លើយឈ្មោះ [redacted] ជឿន ថា កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ នោះ បក្សពួកខ្លួន ៧នាក់ ចូលប្លន់ភូមិអាងសិលា គឺមានឈ្មោះ វុធដា កាន់អាកាបត់, ឈ្មោះ [redacted] សារ៉ាន់ កាន់អាវុធខ្លីម៉ាករូឡូ, ឈ្មោះ [redacted] សុត្រ កាន់កា៥៤, ឈញមោះ [redacted] សារង្ស កាន់គ្រាប់បែកដៃ, ឯខ្លួន និង សុខខែម គ្មានអាវុធទេ គេឲ្យចាំផ្លូវ។ លុះប្លន់ផ្ទះកាំភ្លើង និងគ្រាប់បែក ខ្លួនក៏រត់គេច។

៤. ជនត្រូវចោទឈ្មោះ [redacted] សារ៉ាន់ និងឈ្មោះ [redacted] ជឿន នេះ ត្រូវបានចៅក្រមស៊ើបអង្កេតសាលាដំបូង ខេត្តបន្ទាយមានជ័យ សម្រេចលើកលែងចោទ តាមដីកាលេខ ២៧ ដអក ចុះថ្ងៃទី១៨ ខែមីនា ឆ្នាំ២០០៤ ចំពោះឈ្មោះ [redacted] សារ៉ាន់, និងដីកាលេខ ៤៤ ដអក ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០០៤ ចំពោះឈ្មោះ [redacted] ជឿន

៥. តាមចម្លើយដើមបណ្តឹងរដ្ឋប្បវេណី ដែលបានឆ្លើយនៅសវនាការសាលាឧទ្ធរណ៍ កាលពីថ្ងៃទី១៦ ខែកុម្ភៈ ឆ្នាំ២០០៩ ថា មុនពេលកើតហេតុភ្លាម កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ ខ្លួនឃើញមនុស្សបីនាក់ ដែលខ្លួនស្គាល់ច្បាស់ ព្រោះពួកវាធ្លាប់រកស៊ីជាមួយប្តីខ្លួន គឺមានឈ្មោះ [redacted] សុត្រ, ឈ្មោះ [redacted] សារ៉ាន់ និង ឈ្មោះ [redacted] ជឿន បានដើរចូលទៅក្នុងផ្ទះខ្លួន ហើយប្រាប់ខ្លួនថា កុំឲ្យមាត់ នៅឲ្យស្ងៀម គ្នាឯងទេ, ភ្លាមនោះ ស្រាប់តែពួកវាចាប់ធ្វើសកម្មភាព បានញ់សម្លាប់ប្តីខ្លួនឈ្មោះ [redacted] ចាន់ និងឈ្មោះ [redacted] ឡាង បណ្តាលឲ្យ ស្លាប់ភ្លាមនៅនឹងកន្លែង។ ខ្លួនមិនបានឃើញមនុស្សផ្សេង ក្រៅពីមនុស្សបីនាក់នេះ ដែលចូលទៅប្លន់ និងបាញ់ សម្លាប់ប្តីខ្លួននៅពេលនោះទេ គ្មានអ្នកផ្សេងឡើយ។

៦. តាមន័យនេះ ឃើញថាករណីប្លន់សម្លាប់ជនរងគ្រោះ កាលពីថ្ងៃទី១៥ ខែមករា ឆ្នាំ២០០៤ នៅភូមិ សិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ មិនពាក់ព័ន្ធនឹងជនជាប់ចោទឈ្មោះ [redacted] សុខខែម នេះឡើយ ថ្វីបើជនត្រូវចោទឈ្មោះ [redacted] សារ៉ាន់ និងឈ្មោះ [redacted] ជឿន ដែលឆ្លើយនៅសមត្ថកិច្ចនគរបាលថា ឈ្មោះ [redacted] សុខខែម នៅចាំផ្លូវខាងជើងក៏ដោយ គឺគ្រាន់តែជាចម្លើយឆ្លើយដាក់ ដែលជនទាំងពីរនាក់នេះថា ជា ចម្លើយកើតឡើងដោយមានការបង្ខិតបង្ខំ។

៧. យោងតាមមាត្រា ៣៨ នៃច្បាប់រដ្ឋធម្មនុញ្ញ គួរឲ្យជនជាប់ចោទរួចផុតពីបទចោទ។

៨. ចំណុចទី៣ នៃសាលដីកាព្រហ្មទណ្ឌលេខ ២៣ «ខ» ចុះថ្ងៃទី០៤ ខែមីនា ឆ្នាំ២០០៨ របស់ សាលាឧទ្ធរណ៍ សម្រេចមានការខុសឆ្គង គួរបដិសេធចោល ហើយសម្រេចឡើងវិញ ដូចយល់ឃើញខាងលើ។

## ហេតុដូច្នេះ

## វិនិច្ឆ័យសេចក្តី

១. ទទួលបណ្តឹងទាស់លេខ ១៦ ចុះថ្ងៃទី០៥ ខែសីហា ឆ្នាំ២០១៣ របស់ឈ្មោះ [redacted] សុខខែម ជាជនត្រូវចោទ ទុកជាត្រឹមត្រូវតាមទម្រង់ និងគតិច្បាប់។

២. បដិសេធចំណុចទី៣ នៃសេចក្តីវិនិច្ឆ័យ នៃសាលដីកាព្រហ្មទណ្ឌលេខ ២៣ «ខ» ចុះថ្ងៃទី ០៤ ខែមីនា ឆ្នាំ២០០៨ របស់សាលាឧទ្ធរណ៍ ចោលជាអសារបង់។

៣. ឲ្យឈ្មោះ [redacted] សុខខែម ជាជនត្រូវចោទ អាយុ៤៦ឆ្នាំ ភេទប្រុស ជាតិខ្មែរ ទីកន្លែងកំណើត នៅភូមិគគរ ឃុំគគរ ស្រុកក្រចេះ ខេត្តក្រចេះ លំនៅមុនចាប់ខ្លួន នៅភូមិអូរឫស្សី ឃុំប៉ោយប៉ែត ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យរួចផុតពីបទចោទប្រកាន់ ក្នុងបទ ឃាតកម្មគិតទុកជាមុន និងប្រើប្រាស់អាវុធខុសច្បាប់ ប្រព្រឹត្តនៅភូមិសិលាខ្មែរ ឃុំអូរបីជាន់ ស្រុកអូរជ្រៅ ខេត្តបន្ទាយមានជ័យ កាលពីថ្ងៃទី១៥ ខែមករាឆ្នាំ២០០៤ បទល្មើសមានចែង និងឲ្យផ្ដន្ទាទោសតាមមាត្រា៣ នៃច្បាប់ស្ដីពីស្ថានទម្ងន់ទោសនៃបទឧក្រិដ្ឋ និងមាត្រា៥៤ នៃច្បាប់ព្រហ្មទណ្ឌអន្តរកាល។

៤. បង្គាប់ឲ្យដោះលែងឈ្មោះ [redacted] សុខខែម នេះចេញពីបន្ទប់ឃុំឃាំងភ្លាម បើឈ្មោះនេះពុំបានត្រូវឃុំឃាំងពីបទអ្វីផ្សេងទៀតទេ។

សាលដីកានេះ ជំនុំជម្រះជាសាធារណៈ នៅថ្ងៃទី១៣ ខែធ្នូ ឆ្នាំ២០១៣ ប្រកាសជាសាធារណៈ នៅថ្ងៃទី២៦ ខែធ្នូ ឆ្នាំ២០១៣ ចំពោះមុខជនត្រូវចោទឈ្មោះ [redacted] សុខខែម និងមេធាវីការពារជនត្រូវចោទ, បើកផ្លូវសាទុក្ខ ០១ខែ គិតចាប់ពីថ្ងៃប្រកាសសាលដីកានេះ។

**សេចក្ដីនេះ ព្រះមហាក្សត្រនៃព្រះរាជាណាចក្រកម្ពុជា ទ្រង់ត្រាស់បង្គាប់មកមន្ត្រីទទួលបន្ទុកអនុវត្តសាលដីកា និងស្ថាប័នមានសមត្ថកិច្ចគ្រប់ថ្នាក់ និងកងកម្លាំងគ្រប់ថ្នាក់គ្រប់តំណែង ជួយសហការអនុវត្តសាលដីកានេះ ឲ្យបានសម្រេច បើមានសំណូមពរត្រឹមត្រូវតាមច្បាប់។៚**

| ក្រឡាបញ្ជី | ចៅក្រមប្រឹក្សា | ប្រធានក្រុមប្រឹក្សា |
|---|---|---|
| ហត្ថលេខា: [redacted] | ហត្ថលេខា: [redacted], [redacted] | ហត្ថលេខា: [redacted] |

---

| | |
|---|---|
| បានឃើញ | ចម្លងចេញត្រឹមត្រូវតាមច្បាប់ដើម |
| **ប្រធានសាលាឧទ្ធរណ៍** | ភ្នំពេញ, ថ្ងៃទី ០៤ ខែ ...០៦. ឆ្នាំ ២០១៤ |
| | **ក្រឡាបញ្ជី** |
| [redacted] | [redacted] |